ស្ថានទូតជប៉ុន
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ. 34 PR-17/EoJ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

## ពិធីចុះហត្ថលេខាលើលិខិតប្តូរសារស្តីពីការផ្តល់ជំនួយឥតសំណងរបស់ជប៉ុន

ថ្ងៃសុក្រ ទី២៧ ខែតុលា ឆ្នាំ២០១៧ ម៉ោង១៤:៣០ រសៀល
នៅសាល"ក" ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

ឆ្លើយតបទៅនឹងសំណើរសុំរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការស្បៀងអាហារពិភពលោក(WFP) រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់ជំនួយឥតសំណងដែលមានទឹកប្រាក់សរុបបីរយហាសិបលានយ៉េន **(¥350,000,000)** ឬ ប្រមាណជា បីលានពីរសែនដុល្លាអាមេរិក **(USD3,200,000)** ជូនរាជរដ្ឋាភិបាលកម្ពុជាតាមរយៈអង្គការ WFP ក្នុងគោលបំណងរួមចំណែកអនុវត្តកម្មវិធីផ្តល់អាហារនៅតាមសាលារៀន។

លិខិតប្តូរសារនៃគម្រោងជំនួយឥតសំណងនេះត្រូវបានចុះហត្ថលេខារវាង **លោកស្រី ណានស៊ី វ៉ាល់ធើ** តំណាងអង្គការWFPប្រចាំនៅកម្ពុជា និង**ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមាន **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា នៅម៉ោង១៤:៣០ រសៀល ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នៅសាល "ក" ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។

នៅក្នុងគម្រោងនេះ ត្រីខកំប៉ុងប្រមាណ**420**តោននឹងត្រូវបានផ្តល់ជូនសម្រាប់អាហារពេលព្រឹករបស់សិស្សសាលានៅតាមសហគមន៍ក្រីក្របំផុត។ ជំនួយឥតសំណងដែលរដ្ឋាភិបាលជប៉ុនបានផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជាតាមរយៈអង្គការWFPមានបំណងលើកស្ទួយសន្តិសុខស្បៀង និងការទទួលបានការអប់រំក្នុងព្រះរាជាណាចក្រកម្ពុជា និង ពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
**លេខ 194 មហាវិថីព្រះនរោត្តម ☎ (023) 217.161-4 ទូរសារ: (023) 214.330**
**អ៊ីមែល: eco.jpn@pp.mofa.go.jp**
**គេហទំព័រ: www.kh.emb-japan.go.jp**

# សុន្ទរកថារបស់ឯកឧត្តម HORINOUCHI Hidehisa ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើ លិខិតប្តូរសារស្តីពីការផ្តល់ជំនួយឥតសំណងរបស់ជប៉ុន ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

- សូមគោរព **ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
- សូមគោរព **លោកស្រី ណានស៊ី វ៉ល់ធើ** តំណាងអង្គការWFP ប្រចាំកម្ពុជា
- សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស អស់លោក លោកស្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ដែលបានចុះហត្ថលេខាជាមួយតំណាងអង្គការWFPលើលិខិតប្តូរសារសម្រាប់ជំនួយឥតសំណងក្នុងកម្មវិធីជំនួយស្បៀងអាហារ។

ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុន ក្នុងពិធីនេះ។

នៅក្នុងកម្មវិធីនេះ រដ្ឋាភិបាលជប៉ុននឹងផ្តល់ជំនួយឥតសំណងជាទឹកប្រាក់សរុប350លានយ៉េន ឬ ប្រមាណ3លាន2សែនដុល្លារអាមេរិក ដើម្បីទិញត្រីខកំប៉ុងប្រមាណ420តោន សម្រាប់អាហារពេលព្រឹករបស់សិស្សសាលានៅសហគមន៍ក្រីក្របំផុតតាមរយៈអង្គការWFP។

សេដ្ឋកិច្ចកម្ពុជាបានកើនឡើងខ្លាំងក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ហើយអត្រានៃភាពក្រីក្របានថយចុះគួរឲ្យកត់សម្គាល់។ ក៏ប៉ុន្តែ ជាពិសេសនៅតំបន់ជនបទ ប្រជាជនមួយភាគធំនៅតែរងគ្រោះពីកង្វះអាហារូបត្ថម្ភពីព្រោះពួកគេមិនមានអាហារគ្រប់គ្រាន់។ ភាគច្រើននៃប្រជាជនទាំងនេះគ្រាន់តែស្ថិតនៅពីលើបន្ទាត់ភាពក្រីក្រហើយមានហានិភ័យខ្ពស់ក្នុងការធ្លាក់ចូលភាពក្រីក្រប្រសិនបើមានបញ្ហាតិចតួចបំផុតកើតឡើងចំពោះប្រាក់ចំណូលរបស់ពួកគេ។

ក្នុងស្ថានភាពនេះ តាមរយៈការផ្តល់ត្រីខកំប៉ុងសម្រាប់កម្មវិធីផ្តល់អាហារនៅតាមសាលារៀនរបស់អង្គការWFP ជំនួយរបស់ជប៉ុនរួមចំណែកក្នុងការលើកស្ទួយសន្តិសុខស្បៀង និងការទទួលបានការអប់រំនៅសាលារបស់កុមារ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ជំនួយរបស់ជប៉ុននឹងត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពដើម្បីធានាបាននូវអនាគតដ៏ល្អសម្រាប់កុមារ។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និងកម្ពុជា។

សូមអរគុណ!